ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ : ៣៥០
ចុះថ្ងៃទី ១៩ ០៥ ០៦
សាលដីកា
លេខ : ៨៦ "ឧ"
ចុះថ្ងៃទី ១៤ ០៧ ០៩

តាមនាមប្រជារាស្ត្រខ្មែរ

សាលាឧទ្ធរណ៍ភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ១៤-០៧-២០០៩ ដោយមានសមាសភាពដូចខាងក្រោម:

**ក្រុមប្រឹក្សាជំនុំជម្រះ**

- លោក [redacted] ជាប្រធានក្រុមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជី**

កញ្ញា [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ: ៣៥០ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៦ ដែលមាន:

- ជនជាប់ចោទឈ្មោះ [redacted]សំអន ភេទប្រុស អាយុ ៣០ឆ្នាំ ជាតិខ្មែរ មុខរបរកាត់សក់ កើតនៅភូមិព្រៃគុយ សង្កាត់លេខ៧ ស្រុកទីរួមខេត្ត ខេត្តកំពង់ធំ ទីលំនៅសព្វថ្ងៃភូមិ[redacted] ខេត្តកំពង់ធំ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ[redacted] មានកូន ២នាក់ ទោសពីមុនគ្មាន ចាប់ខ្លួនថ្ងៃទី១៨-១០-២០០៥ ឃុំខ្លួនថ្ងៃទី២០-១០-២០០៥។

លោក [redacted]បុល មេធាវីការពារ។

**ត្រូវជាប់ចោទពីបទ:** ពីបទ មនុស្សឃាតគិតទុកជាមុន ប្រព្រឹត្តនៅភូមិព្រៃគុយ ឃុំព្រៃគុយ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ កាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៥ តាមមាត្រា ៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

- **ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ** [redacted] យឿន ភេទស្រី អាយុ ២៦ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ ទីលំនៅសព្វថ្ងៃភូមិព្រៃគុយ ឃុំព្រៃគុយ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ។

- តាមពាក្យបណ្តឹងឧទ្ធរណ៍លេខ ២៥ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៦ របស់ជនជាប់ចោទឈ្មោះ [redacted] សំអន ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ១៦ ក ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៦ របស់តុលាការខេត្តកំពង់ធំ គ្រប់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

**ដំណើររឿងមានដូចតទៅ:**

កាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៥ វេលាម៉ោង១៥និង៣០នាទី ជនជាប់ចោទឈ្មោះ [redacted] **សំអន** កំពុងអង្គុយមើលឈ្មោះ [redacted] ប៉ោង និង [redacted] សុឃីម លេងបុកប៊ីយ៉ានៅផ្ទះឈ្មោ[redacted] កុយ ស្រាប់តែជនរងគ្រោះឈ្មោះ [redacted] ផុន ជិះកង់មកដល់ជេរជនជាប់ចោទថា អាពោក ធ្វើឱ្យជនជាប់ចោទដែលធ្លាប់តែទទួលរងនូវការជេរលក្ខិះបែបនេះ ច្រើនលើកច្រើនសារពីជនរងគ្រោះកន្លងមកផងនោះ ខឹងខ្លាំងក៏ដើរទៅយកកាំបិតផ្គាក់ពីផ្ទះចម្ងាយប្រហែលជាង១០០ម៉ែត្រ មកកាប់ឈ្មោះ [redacted] ផុន ២កាំបិតចំក្បាល កាប់ឈ្មោះ[redacted] សុឃីម ១កាំបិត ត្រូវដាច់ឆ្អឹងកំភួនដៃឆ្វេង ហើយដេញតាមកាប់ឈ្មោ[redacted]ផុន ត្រូវច្រើនកាំបិត ដួលស្លាប់ចម្ងាយពីតាបប៊ីយ៉ា៥៦ម៉ែត្រ។

- បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ១៦ ក ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៦ របស់តុលាការខេត្តកំពង់ធំ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ:

១- សម្រេចកែតម្រូវបទល្មើសចោទប្រកាន់លើឈ្មោះ[redacted] **សំអន** ពីបទ មនុស្សឃាតដោយចេតនា តាមមាត្រា ៤ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋឱ្យត្រូវទៅនឹងអំពើល្មើសឃាតកម្មគិតទុកជាមុន តាមមាត្រា ៣ នៃច្បាប់ដដែលនេះវិញ។

២- ផ្តន្ទាទោសឈ្មោះ [redacted] **សំអន** ភេទប្រុស អាយុ ៣០ឆ្នាំ ដាក់ពន្ធនាគារកំណត់ ១៥ឆ្នាំ គិតពីថ្ងៃចាប់ខ្លួនថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៥ ពីបទ ឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅភូមិព្រៃគុយ ឃុំព្រៃគុយ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ កាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៥។

បទល្មើស ព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

៣- វត្ថុតាងមាន: កាំបិតផ្គាក់ដាប់ចំនួន ១ មានចង្កំ១២ ក្រចាប់ចំនួន១ និងមានដែកបន្ទះចំនួន១ ពហើស ផ្ទៃប្រវែង៤០សម ដងប្រវែង៣៥សម ត្រូវរឹបអូសបំផ្លាញចោល។

៤- សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខគូភាគី បើភាគីណាមិនសុខចិត្ត មានសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេល២ខែ តាមកំណត់ច្បាប់ ។

- បានឃើញ ពាក្យបណ្តឹងឧទ្ធរណ៍លេខ ២៥ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៦ របស់ជនជាប់ចោទឈ្មោះ [redacted] **សំអន** ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ១៦ ក ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៦ របស់តុលាការខេត្តកំពង់ធំ គ្រប់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការសាលាឧទ្ធរណ៍។

- បានឃើញរបាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍។

**នាពេលសវនាការ**

ចៅក្រមអានរបាយការណ៍រឿង

ប្រធានក្រុមប្រឹក្សាអានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឆ្លើយនៅតុលាការខេត្តកំពង់ធំ ។

ជនជាប់ចោទ [redacted] សំអន ឆ្លើយថា: ក្នុងរឿងនេះ ខ្លួនពិតជាបានប្រព្រឹត្តមែន ខ្លួនសុខចិត្តទទួលទោស ហើយខ្លួនប្តឹងឧទ្ធរណ៍មកនេះ សុំលោកប្រធានសាលាឧទ្ធរណ៍ ធ្វើការបន្ធូរបន្ថយទោសឱ្យខ្លួនផង។



## <u>សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ</u>

ដោយជនជាប់ចោទបានទទួលសារភាពថា ខ្លួនពិតជាបានប្រព្រឹត្តមែន ឃើញថា មានពិរុទ្ធភាព និងភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោះ [redacted] **សំអន** ពីបទ មនុស្សឃាតគិតទុកជាមុន ប្រព្រឹត្តនៅភូមិព្រៃគុយ ឃុំព្រៃគុយ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ កាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៥ តាមមាត្រា ៣ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។ យល់ឃើញថា សំអាងហេតុរបស់តុលាការខេត្តកំពង់ធំ មានលក្ខណៈត្រឹមត្រូវ គប្បីរក្សាទុកជាបានការ ដូចនេះសន្និដ្ឋានសម្រេចតម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៦ ក ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៦ របស់តុលាការខេត្តកំពង់ធំ ទុកជាបានការដដែល។

## <u>សេចក្ដីសន្និដ្ឋានរបស់មេធាវី</u>

កូនក្ដីខ្លួនបានឆ្លើយសារភាពថា បានប្រព្រឹត្តបទល្មើសពិតមែន តែដោយការប្រព្រឹត្តនេះជាលើកទី១ ដូច្នេះ សុំតុលាការបន្ធូរបន្ថយទោសឱ្យកូនក្ដីខ្លួនផង។

- ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ
- ក្រោយពីបានស្ដាប់អំណានចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ
- ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់

## <u>សាលាឧទ្ធរណ៍ភ្នំពេញ យល់ឃើញថាៈ</u>

១- បណ្ដឹងឧទ្ធរណ៍លេខ ២៥ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៦ របស់ជនជាប់ចោទឈ្មោះ [redacted] សំអន ធ្វើឡើងនៅក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះតាមមាត្រា ១៧៨ នៃច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌ និងមាត្រា ៦០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២- ជនជាប់ចោទបានឆ្លើយសារភាពថា កាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៥ ខ្លួនពិតជាកាប់ជនរងគ្រោះ ជាប្អូនថ្លៃខ្លួន បណ្ដាលឱ្យស្លាប់ប្រាកដមែន ដោយសារខ្លួនមានកំហឹងខ្លាំងពេក ព្រោះជនរងគ្រោះជេរប្រមាថខ្លួន ផ្ដេផ្ដាសដាក់ខ្លួនធ្វើឱ្យខ្លួនមានការឈឺចាប់យ៉ាងខ្លាំង។ នៅពេលកើតហេតុ ជនរងគ្រោះកំពុងលេងបុកបៀយ៉ាមិនដឹងខ្លួន ខ្លួនក៏កាប់ក្បាល១ កាំបិត និងខ្នង១កាំបិតទៀត ជនរងគ្រោះ[redacted]ផុន រត់គេចរួចតែខ្លួនដេញកាប់រហូតដល់ស្លាប់តែម្ដង។

៣- មានពិរុទ្ធភាពលើជនជាប់ចោទ ពីបទ ឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅភូមិព្រៃគុយ ឃុំព្រៃគុយ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ កាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៥ បទល្មើសមានចែង និងឱ្យផ្ដន្ទាទោសតាមមាត្រា ៣ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

៤- សាលក្រមព្រហ្មទណ្ឌលេខ ១៦ ក ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៦ របស់សាលាដំបូងខេត្តកំពង់ធំ សម្រេចត្រឹមត្រូវតាមច្បាប់ គួរតម្កល់ទុកជាបានការ។

## ហេតុបច្នេះ

## វិនិច្ឆ័យសេចក្តី

១- ទទួលបណ្តឹងឧទ្ធរណ៍លេខ ២៥ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៦ របស់ឈ្មោះ [redacted] សំអន ជាជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៦ ក ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៦ របស់សាលាដំបូងខេត្តកំពង់ធំ ទុកជាបានការពេញទាំងមូល ។

៣- បង្គាប់ឱ្យបន្តការឃុំខ្លួនជនជាប់ចោទបន្តទៀត ។

សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ និងមេធាវីការពារជនជាប់ចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវតវ៉ាតាមកំណត់ច្បាប់ ។

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការ អនុវត្ត សាលដីកានេះឱ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។ ៗ

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា: | ហត្ថលេខា: | ហត្ថលេខា: |
| [redacted] | [redacted] | [redacted] |

---

បានឃើញ
ប្រធានសាលាឧទ្ធរណ៍

[redacted]

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី 27 ខែកុម្ភៈ ឆ្នាំ២០១៤
ក្រឡាបញ្ជី

[redacted]